# ជំនឿ Faith

អ្នកនិពន្ធ រ៉ូហ្វ លេភិឡារ

## *សេចក្តីផ្តើម៖ សារៈសំខាន់នៃជំនឿ* Introduction: The Importance of Faith

សេចក្តីជំនឿមាននិយាយជាង៥០០ដង ក្នុងសញ្ញាថ្មីទាំងមូល។ ការនេះបង្ហាញថា វាមានសារៈសំខាន់ណាស់ក្នុងជីវិតរបស់គ្រីស្ទបរិស័ទ។ ហេព្រើរ ១១:៦ បានសរសេរថា «បើឥតមានសេចក្តីជំនឿទេ នោះមិនអាចនឹងគាប់ដល់ព្រះហឫទ័យព្រះបានឡើយ»។

សេចក្តីជំនឿ គឺជាស្នូលនៃទំនាក់ទំនងរបស់យើងជាមួយព្រះ។ ខ្ញុំធ្លាប់សួរសិស្សថា តើអ្វីគឺជាសារៈសំខាន់ ចំពោះព្រះ គេតែងតែឆ្លើយថា គឺការស្តាប់បង្គាប់របស់យើង ប៉ុន្តែជាច្រើនដង គេមិនឆ្លើយថា ជាសេចក្តីជំនឿរបស់យើងនោះឡើយ។ ការនេះបង្ហាញថា ក្នុងចំណោមសិស្សមានការយល់ច្រឡំអំពីព្រះ។ ព្រះមិនមែន គ្រាន់តែជាព្រះនៃសីលធម៌ដែលទាមទារអោយយើងជាមនុស្សល្អប៉ុណ្ណោះទេ ទ្រង់ជាព្រះដែលចង់បានទំនាក់ទំនងជិតស្និទ្ធជាមួយយើង ហើយទំនាក់ទំនងនោះគឺស្ថិតនៅលើសេចក្តីជំនឿ។ មានផ្លូវតែមួយប៉ុណ្ណោះដែលអាចចូលទៅក្នុងទំនាក់ទំនងជាមួយព្រះបាន ហើយវាគឺដោយសារផ្លូវដែលព្រះទ្រង់ផ្ទាល់ជាអ្នកប្រទានអោយ។ ផ្លូវដែលព្រះប្រទានអោយមានទំនាក់ទំនងជាមួយទ្រង់ គឺដោយសារដំណឹងល្អនៃព្រះគ្រីស្ទ និងការឆ្លើយតបដែលសមស្រប ដែលព្រះត្រាស់ហៅយើងអោយជឿក្នុងព្រះយេស៊ូវ។ ហេតុដូច្នេះ បើគ្មានជំនឿលើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ក៏គ្មានទំនាក់ទំនងជាមួយព្រះដែរ។

អាស្រ័យហេតុនេះ ជំនឿ គឺជាស្នូលនៃសេចក្តីសង្គ្រោះរបស់យើង។ សញ្ញាថ្មីច្បាស់ណាស់ថា មានតែតាមរយៈជំនឿក្នុងព្រះយេស៊ូវប៉ុណ្ណោះដែលមនុស្សអាចចូលក្នុងជីវិតអស់កល្បជានិច្ចបាន (យ៉ូហាន ៣:១៦)។ ដោយសារសេចក្តីជំនឿគឺជាគ្រឹះនៃសេចក្តីសង្គ្រោះរបស់យើង ដូច្នេះជាការសំខាន់ណាស់ ដែលយើងត្រូវយល់អំពីសេចក្តីជំនឿ។ សេចក្តីជំនឿ គឺជាស្នូលនៃជីវិតជាគ្រីស្ទបរិស័ទរបស់យើង (កាឡាទី ២:២០)។ សេចក្តីជំនឿលើព្រះយេស៊ូវ មិនមែនគ្រាន់តែជាឧបករណ៍អោយយើងយកសេចក្តីសង្គ្រោះពីទ្រង់ប៉ុណ្ណោះទេ ប៉ុន្តែជាការបន្តរស់នៅក្នុងជីវិតជាមួយទ្រង់ជានិច្ច។

## *តើសេចក្តីជំនឿគឺជាអ្វី?* What is Faith?

ពាក្យថា «ជឿ» ត្រូវបានប្រើប្រាស់តាមរបៀបខុសគ្នាជាច្រើន។ បើនិយាយថា «ខ្ញុំជឿថា ១+១=២» វាខុសពីការនិយាយថា "ខ្ញុំជឿលើលទ្ធិប្រជាធិបតេយ្យ" ហើយទាំងពីរក៏ខុសពីការនិយាយថា "ខ្ញុំជឿលើព្រះយេស៊ូវ" ដែរ។ តើពាក្យថាជឿមានអត្ថន័យខុសគ្នាដូចម្តេចខ្លះក្នុងឃ្លាប៉ុន្មានខាងលើនេះ?
ចូរអាន រ៉ូម ៤:១៨-២១ តើខទាំងនេះពន្យល់អ្វីខ្លះពីជំនឿរបស់លោកអាប្រាហាំ?

ទីមួយ សេចក្តីជំនឿរបស់លោកអាប្រាហាំ គឺជាការឆ្លើយតបចំពោះសេចក្តីសន្យារបស់ព្រះ ដែលព្រះបានបើកសម្តែងរួចហើយដល់លោកអាប្រាហាំតាមរយៈព្រះបន្ទូលរបស់ទ្រង់។ ដូច្នេះ សេចក្តីជំនឿ គឺជាការឆ្លើយតបចំពោះ ព្រះរាជសាររបស់ព្រះដែលបានប្រកាសដោយព្រះបន្ទូលទ្រង់រួចហើយ។ ការនេះបង្ហាញថា មនុស្សមិនអាចមានសេចក្តីជំនឿបានទេ បើគេមិនបានលឺដំណឹងល្អ (រ៉ូម ១០:១៧)។ ទីពីរ យើងមើលឃើញនៅរ៉ូម ៤:១៨-២១ ថា សេចក្តីជំនឿនាំអោយមានសេចក្តីសង្ឃឹម។ នៅក្នុងព្រះគម្ពីរ សេចក្តីជំនឿ តែងតែសំឡឹងឆ្ពោះទៅអនាគត ហើយទន្ទឹងរងចាំសេចក្តីសន្យារបស់ព្រះត្រូវបានសំរេច។ នេះជាអ្វីដែល ហេព្រើរ ១១ បង្រៀនយ៉ាងច្បាស់។

ចូរអានរ៉ូម ១០:១៤-១៧ តើមនុស្សអាចជឿបានដោយរបៀបណា?

ដូច្នេះយើងឃើញថា ការយល់ដឹងរបស់យើងអំពីសេចក្តីជំនឿ និងការយល់ដឹងអំពីការបើកសម្តែង និងអំពីព្រះមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយគ្នា។ តាមព្រះគម្ពីរ សេចក្តីជំនឿ គឺជាការឆ្លើយតបទៅព្រះ ដែលទ្រង់បានសម្តែងព្រះអង្គទ្រង់ និងសម្តែងការសន្យាតាមរយៈព្រះបន្ទូល។ ហេតុដូច្នេះ មនុស្សម្នាក់ពុំអាចមានជំនឿទេ បើសិនជាគេមិនបានលឺដំណឹងល្អរបស់ព្រះយេស៊ូវ ព្រោះតាមព្រះគម្ពីរ សេចក្តីជំនឿ គឺជាសេចក្តីជំនឿលើព្រះគ្រីស្ទ (យ៉ូហាន ៣:១៦; ១យ៉ូហាន ៣:២៣)។

សូមអាន ហេព្រើរ ១១:១ តើសេចក្តីជំនឿជាអ្វី?

សូមអាន ហេព្រើរ ១១:១៣-១៦ តើយើងរៀនបានអ្វីខ្លះពីមនុស្សដែលមានសេចក្តីជំនឿទាំងនេះ?

សូមកត់សម្គាល់មើលម្តងទៀត សេចក្តីជំនឿ ជាដំណើរឆ្ពោះទៅមុខ។ សេចក្តីជំនឿ ជាការរងចាំដោយសេចក្តីសង្ឃឹមយ៉ាងជាក់លាក់សំរាប់អ្វីដែលព្រះបានសន្យា និងអ្វីដែលយើងមិនទាន់បានទទួលនៅឡើយ។

អាស្រ័យហេតុនេះ នៅក្នុងរ៉ូម ១០:១៤-១៧ យើងមើលឃើញថា សេចក្តីជំនឿជាប់ទាក់ទិននឹង *ចំណេះដឹងអំពីអ្វីដែលយើងដាក់សេចក្តីជំនឿលើនោះ ។* មនុស្សត្រូវតែដឹងច្បាស់ពីការពិតអំពីព្រះយេស៊ូវ ដើម្បីអោយគេអាចទុកចិត្តទ្រង់បាន។ បើគ្រាន់តែផ្តោតការសញ្ជប់សញ្ជឹងលើការបង្កើតដើម្បីអោយដឹងថា មានអ្នកបង្កើត នោះមិនគ្រប់គ្រាន់ដើម្បីអោយមានសេចក្តីជំនឿឡើយ។

សេចក្តីជំនឿក៏មានទាក់ទិននឹងការយល់ព្រមអំពីចំណេះដឹងផងដែរ។ ដូច្នេះ សេចក្តីជំនឿ មានទាក់ទិននឹងការយល់អោយបានត្រឹមត្រូវអំពីព្រះ និងជឿលើសេចក្តីពិតដែលត្រឹមត្រូវ ដែលគេបានរៀនពីព្រះបន្ទូលរបស់ព្រះ។ ម្តងទៀត ទោះយ៉ាងណា វាមិនទាន់គ្រប់គ្រាន់ទេ (កិច្ចការ ២៦:២៧-២៨)។

សេចក្តីជំនឿក៏ទាក់ទិននឹងការមានទំនុកចិត្តដែរ។ នៅក្នុងព្រះគម្ពីរ ការជឿលើព្រះយេស៊ូវមានអត្ថន័យច្រើនរួមទាំងយើងទុកចិត្តលើព្រះយេស៊ូវ។

ដោយសារពាក្យជំនឿមានអត្ថន័យច្រើនពីគ្នា អ្នកនិពន្ធផ្សេងៗប្រើពាក្យជំនឿរបៀបផ្សេងៗគ្នាដែរ។ នេះជាមូលហេតុមួយដែលនាំអោយយើងហាក់មើលឃើញថា លោកប៉ូល និងលោកយ៉ាកុបមានភាពផ្ទុយពីគ្នា។ លោកប៉ូលនិយាយថាយើងបានរាប់ជាសុចរិតដោយសារសេចក្តីជំនឿតែមួយគត់ (រ៉ូម ៤:១-៥, កាឡាទី ២-៣) រីឯលោកយ៉ាកុបថា យើងមិនត្រឹមតែត្រូវបានរាប់ជាសុចរិតដោយសារសេចក្តីជំនឿតែម្យ៉ាងនោះឡើយ ប៉ុន្តែដោយសារសេចក្តីជំនឿ និងការប្រព្រឹត្ត។ ទោះយ៉ាងណា គាត់ទាំងពីរប្រើពាក្យ*សេចក្តីជំនឿ*ខុសពីគ្នា។ ក្នុងការនិពន្ធរបស់លោកប៉ូល គាត់មិនដែលនិយាយពីសេចក្តីជំនឿថា គ្រាន់តែជាការទទួលយកបែបបញ្ញាប៉ុណ្ណោះឡើយ។ ទោះយ៉ាងណា លោកយ៉ាកុបកំពុងសរសេរប្រឆាំងនឹងការយល់ថា សេចក្តីជំនឿ គ្រាន់តែជាការទទួលយកបែបបញ្ញានោះឯង។ អញ្ចឹងហើយបានជាក្នុងការពិភាក្សារបស់លោក គាត់ប្រើពាក្យ សេចក្តីជំនឿ ដើម្បីមានន័យថា ជំនឿគឺគ្រាន់តែជាការទទួលយកបែបបញ្ញាប៉ុណ្ណោះ។ ដូច្នេះ ពេលលោកយ៉ាកុបនិយាយថា សេចក្តីជំនឿដែលគ្មានការប្រព្រឹត្តជាការស្លាប់ (យ៉ាកុប ២:២៦) គឺគាត់កំពុងតែនិយាយដូចគ្នានឹងសញ្ញាថ្មីទាំងមូលរួមទាំងលោកប៉ូលផង (កាឡាទី ៥:៦, ១ធីម៉ូថេ ៥:៨)។ និយាយអោយចំ លោកប៉ូលយល់ស្របថា សេចក្តីជំនឿដែលគ្រាន់តែជាការទទួលយកបែបបញ្ញា នោះវាមិនគ្រប់គ្រាន់ទេ។

ក្នុងបទគម្ពីរទាំងមូលបង្ហាញថា រាស្ត្ររបស់ព្រះរស់នៅដោយសារសេចក្តីជំនឿ ប៉ុន្តែការយល់ដឹងអំពីសេចក្តីជំនឿមានការអភិវឌ្ឍនៅពេលដែលព្រះបើកសម្តែងអំពីសេចក្តីសន្យារបស់ទ្រង់ អំពីព្រះគុណ និងសេចក្តីពិត គឺការបើកសម្តែងដែលជាគ្រឹះនៃសេចក្តីជំនឿនោះកាន់តែរីកធំទៅៗ។ សញ្ញាចាស់អាចសង្ខេបសេចក្តីជំនឿថា ជាការសំរាក ការទុកចិត្ត និងការសង្ឃឹមលើព្រះអម្ចាស់ ការនៅជាប់ជាមួយទ្រង់ រង់ចាំទ្រង់ ការយកទ្រង់ជាខែល និងជាប៉ម និងជ្រកក្នុងទ្រង់។ *ហេតុនេះជារឿយៗ ភាពផ្ទុយពីសេចក្តីជំនឿ មិនមែនគ្រាន់តែការមិនជឿប៉ុណ្ណោះទេ ប៉ុន្តែជាការពឹងអាងខ្លួនឯង ឬក៏ពឹងអាងលើអ្វីផ្សេង ឬនរណាម្នាក់ ជាជាងព្រះសំរាប់អ្វីដែលគួរតែជាការពឹងអាងលើព្រះ។* ឧទាហរណ៍ លោកអេសាយបានបន្ទោសដល់រាស្ត្ររបស់ព្រះថា គេខ្វះសេចក្តីជំនឿពីព្រោះគេទុកចិត្តលើសាសន៍អេស៊ីព្ទដើម្បីសង្គ្រោះគេ ជាជាងទុកចិត្តលើព្រះ។ ហេតុនេះ ជាការសំខាន់ណាស់ ដែលត្រូវសម្គាល់ថា *ទោះបីជាពួកគេបានជឿថា មានព្រះដែលបង្កើតគ្រប់ទាំងអស់ក៏ដោយ ក៏គេនៅតែមិនមានសេចក្តីជំនឿដែរ ព្រោះគេមិនបានដាក់សេចក្តីទុកចិត្តលើទ្រង់សោះ។*

## *សេចក្តីជំនឿលើព្រះយេស៊ូវ សេចក្តីជំនឿលើដំណឹងល្អ* Faith *in* Jesus; Faith *in* the Gospel

យោងទៅតាមព្រះគម្ពីរសញ្ញាថ្មី សេចក្តីជំនឿ មិនគ្រាន់តែជាការជឿថា មានព្រះពិតមែន ហើយក៏មិនគ្រាន់តែជឿលើព្រះនោះទេ ប៉ុន្តែជាការជឿ*លើព្រះគ្រីស្ទ* (១យ៉ូហាន ៣:២៣) ជឿ*ដំណឹងល្អ* (ម៉ាកុស ១:១៥)។ ការយល់ដឹងនេះ មានសារៈសំខាន់ណាស់។ អ្វីៗគ្រប់យ៉ាងដែលព្រះប្រទានអោយនៅក្នុងសេចក្តីសង្គ្រោះ ទ្រង់ប្រទានអោយ*នៅក្នុងព្រះគ្រីស្ទ* ឬនិយាយម្យ៉ាងទៀតថា *តាមរយៈព្រះគ្រីស្ទ*។ សេចក្តីសន្យា ទាំងឡាយមកដល់*នៅក្នុងព្រះគ្រីស្ទ* (២កូរិនថូស ១:២០)។ ហេតុដូចនេះ មិនមែនសេចក្តីជំនឿទេ ដែលសង្គ្រោះយើង ប៉ុន្តែព្រះគ្រីស្ទ ដែលសង្គ្រោះយើង ហើយមធ្យោបាយដែលយើងទទួលយកសេចក្តីសង្គ្រោះ ដែលព្រះគ្រីស្ទប្រទានអោយយើង គឺតាមរយៈសេចក្តីជំនឿ។

ការជឿលើព្រះយេស៊ូវមានន័យថា យើងទុកចិត្តថា ទ្រង់នឹងប្រទាននូវអ្វីៗ ដែលព្រះជាម្ចាស់បានសន្យាជាមួយយើងតាមរយៈទ្រង់។ ព្រះជាម្ចាស់បានសន្យាថា ទ្រង់នឹងសង្គ្រោះយើងតាមរយៈព្រះយេស៊ូវ។ ប្រសិនបើយើងទុកចិត្តលើខ្លួនឯង និងទង្វើល្អរបស់យើងថា អាចជួយសង្គ្រោះខ្លួនយើងបាន នោះមានន័យថា យើងមិនបានទុកចិត្តលើព្រះយេស៊ូវទេ។ ការដែលព្យាយាមធ្វើការនោះដោយខ្លួនឯង មានន័យថាទុកចិត្តលើខ្លួនឯងជាងទុកចិត្តលើទ្រង់។

ឧទាហរណ៍ ប្រសិនបើខ្ញុំចង់បានទូរស័ព្ទដៃមួយគ្រឿង ហើយមិត្តរបស់ខ្ញុំបានប្រាប់ខ្ញុំថា គាត់នឹងទិញទូរស័ព្ទដៃដែលខ្ញុំចង់បាននោះឲ្យខ្ញុំ ហើយខ្ញុំក៏និយាយថាអរគុណ ស្រាប់តែភ្លាមៗនោះ ខ្ញុំបានដើរចូលទៅក្នុងហាងលក់ទូរស័ព្ទ ហើយទិញទូរស័ព្ទដៃមួយដោយខ្លួនឯង តើនេះមានន័យថា ខ្ញុំជឿថាមិត្តរបស់ខ្ញុំនឹងទិញទូរស័ព្ទដៃឲ្យខ្ញុំឬទេ? ទេ មិនទុកចិត្តឡើយ។ នៅពេលខ្ញុំទិញទូរស័ព្ទដៃនោះដោយខ្លួនឯង នោះមានន័យថា ខ្ញុំមិនបានជឿថាមិត្តខ្ញុំនឹងទិញទូរស័ព្ទដៃមួយនោះឲ្យខ្ញុំទេ។ ការនេះ ដូចគ្នានឹងការទុកចិត្តលើព្រះយេស៊ូវដែរ។ ប្រសិនបើយើងព្យាយាមសង្គ្រោះខ្លួនឯងតាមរយៈទង្វើល្អរបស់យើង នោះមានន័យថា យើងមិនបានទុកចិត្តចំពោះសេចក្តីសង្គ្រោះ ដែលព្រះយេស៊ូវបានធ្វើសំរាប់យើងនោះទេ (រ៉ូម ៤:១-៥, ១១:៦)។

១កូរិនថូស ១៥ គឺជាកណ្ឌគម្ពីរដ៏សំខាន់មួយក្នុងការបង្ហាញពីគោលការណ៍នេះ។ នៅក្នុងខ១-៤ សាវកប៉ុលបានរំលឹកពួកគេអំពីដំណឹងល្អ ទាក់ទងនឹងការសុគត និងការរស់ពីសុគតឡើងវិញរបស់ព្រះយេស៊ូវ។ ពួកជំនុំកូរិនថូសបានជឿលើ

ដំណឹងល្អនេះ ហើយតាមរយៈដំណឹងល្អនេះឯងដែលយើងរាល់គ្នាបានសង្គ្រោះ។ ដូច្នេះជំនឿ គឺមាននៅក្នុងព្រះគ្រីស្ទ និង នៅក្នុងដំណឹងល្អ។

ការនេះបានចែងយ៉ាងច្បាស់ ប៉ុន្តែសមាជិកជាច្រើននៅក្នុងពួកជំនុំបានភ្លេចពីការនេះ។ ពួកគេគិតថា ជំនឿគឺគ្រាន់តែជឿថាមានព្រះជាម្ចាស់ នោះជាការស្រេច។ ក្រោយពេលដែលគ្រីស្ទបរិស័ទខ្មែរ និយាយជាមួយខ្ញុំទាក់ទងនឹងមិត្តភក្តិរបស់ពួកគេ ឬសាច់ញាតិរបស់ពួកគេ នោះខ្ញុំតែងសួរពួកគេថា «តើគាត់ជាគ្រីស្ទបរិស័ទឬ»? ពួកគេតែងឆ្លើយមកខ្ញុំថា «បាទ ពួកគេជឿព្រះ»។ ខ្ញុំបានឆ្លើយតបទៅពួកគេថា «នោះមិនមែនមានន័យថាពួកគេជាគ្រីស្ទបរិស័ទឡើយ»។ ជំនឿនៅក្នុងព្រះគម្ពីរមិនមែនគ្រាន់តែ ជឿលើព្រះប៉ុណ្ណោះនោះទេ តែត្រូវជឿលើដំណឹងល្អ។

បន្ថែមលើសពីនេះ សាវកប៉ុលបានលើកឡើងនៅក្នុងខ២ថា ប្រសិនបើយើងមិនឈរវឹងមាំនៅក្នុងដំណឹងល្អទេនោះ ជំនឿរបស់យើង នឹងក្លាយជាឥតប្រយោជន៍មិនខាន។ មិនខ្វល់ថាយើងស្មោះត្រង់ចំពោះជំនឿ ឬការថ្វាយបង្គំប៉ុណ្ណានោះឡើយ ប្រសិនបើជំនឿរបស់យើងមិនរឹងមាំនៅក្នុងដំណឹងល្អទេ នោះវានឹងត្រលប់ទៅជាឥតប្រយោជន៍ទទេ។

ប៉ុន្តែ ពួកជំនុំកូរិនថូសបានយល់ច្រឡំចំពោះការនេះ។ នៅក្នុង១កូ. ១៥:១២ យើងបានឃើញថា មានអ្នកខ្លះក្នុងចំណោមពួកគេបានយល់ថា ពួកមនុស្សស្លាប់មិនបានរស់ឡើងវិញឡើយ។ សាវកប៉ុលបានមានប្រសាសន៍ថា ប្រសិនបើមនុស្សស្លាប់មិនបានរស់ពីស្លាប់ឡើងវិញទេ នោះព្រះយេស៊ូវក៏មិនបានរស់ពីសុគតឡើងវិញដែរ (ខ១៣)។

នៅត្រង់នេះសាវកប៉ុលបានលើកឡើងថា ប្រសិនបើព្រះយេស៊ូវមិនបានរស់ពីសុគតឡើងវិញទេ នោះជំនឿរបស់យើងនឹងឥតប្រយោជន៍ (ខ១៤) និងអាសារឥតការមិនខាន (ខ១៧)។

ជាច្រើនដងខ្ញុំបានសួរដល់គ្រីស្ទបរិស័ទជនជាតិខ្មែរថា ប្រសិនបើ ព្រះយេស៊ូវមិនបានរស់ពីសុគតឡើងវិញទេ តើអ្នកនឹងនៅតែជឿលើទ្រង់ ដើរតាមទ្រង់ និងទៅព្រះវិហារទៀតដែរឬទេ? ពេលខ្លះពួកគេមិនដឹងឆ្លើយយ៉ាងម៉េចឡើយ។ ប៉ុន្តែយោងទៅតាមចម្លើយនៅក្នុងអត្ថបទនេះវិញ បានបញ្ជាក់យ៉ាងច្បាស់ថា មិនត្រូវបន្តជឿ ឬដើរតាមទ្រង់ឡើយ។ មានអ្នកខ្លះទៀតសំឡឹងមើលមុខខ្ញុំទាំងភ្ញាក់ផ្អើល នៅពេលឮខ្ញុំនិយាយដូច្នោះ។ ប្រសិនបើមិនដឹងថាឆ្លើយយ៉ាងម៉េចចំពោះសំណួរនោះទេ នោះមានន័យថាខ្វះការយល់ដឹងអំពីជំនឿ។

ហេតុអ្វីបានជាសាវកប៉ុលបានមានប្រសាសន៍ថា ប្រសិនបើព្រះគ្រីស្ទមិនរស់ពីសុគតឡើងវិញ នោះជំនឿរបស់យើងនឹងក្លាយជាឥតប្រយោជន៍យ៉ាងនេះ? ពីព្រោះជំនឿនៅក្នុងព្រះគម្ពីរ មិនមែនគ្រាន់តែជឿថាមានវត្តមានរបស់ព្រះជាម្ចាស់ ទ្រង់ឆ្លើយតបចំពោះសេចក្តីអធិស្ឋានរបស់យើងប៉ុណ្ណោះនោះទេ តែត្រូវជឿលើដំណឹងល្អអំពីព្រះគ្រីស្ទវិញ។ ដំណឹងល្អអំពីព្រះគ្រីស្ទបានប្រកាសអំពីហេតុការណ៍ប្រវត្តិសាស្ត្រដែលថា ព្រះគ្រីស្ទបានសុគត និងបានរស់ពីសុគតឡើងវិញ។ ប្រសិនបើទ្រង់បានសុគត តែមិនបានរស់ពីសុគតឡើងវិញទេ នោះមានន័យថា យើងបានដាក់ជំនឿលើសារក្លែងក្លាយ ហើយជំនឿរបស់យើងក៏ឥតប្រយោជន៍ដែរ។

ប៉ុន្តែ មនុស្សជាច្រើនបានជឿលើព្រះជាម្ចាស់គ្រាន់តែចង់បានជំនួយនៅក្នុងជីវិតនេះតែប៉ុណ្ណោះ។ ពួកគេគិតថា ពួកគេទទួលជឿព្រះជាម្ចាស់ ដើម្បីឲ្យទ្រង់ឆ្លើយតបចំពោះការអធិស្ឋានរបស់ពួកគេ។ ពួកគេអាចមានគំនិតយ៉ាងនេះថា ពួកគេទៅព្រះវិហារពីព្រោះការថ្វាយបង្គំព្រះជាម្ចាស់គឺជារឿងត្រឹមត្រូវ ឬព្រះជាម្ចាស់អាចនឹងប្រទានពរដល់ពួកគេ នៅពេលពួកគេទៅព្រះវិហារ។ ពួកគេអាចមានគំនិតថា ជឿលើព្រះធ្វើឲ្យពួកគេមានសន្តិភាព ដូច្នេះពួកគេនឹងបន្តការជឿ ទោះបីជាព្រះគ្រីស្ទ

មិនបានរស់ពីសុគតឡើងវិញក៏ដោយ។ យោងទៅតាមព្រះគម្ពីរ ការគិតបែបនេះមិនមែនជា «ជំនឿ» នោះទេ។ តាមព្រះគម្ពីរ ជំនឿគឺជាការជឿទៅលើដំណឹងល្អអំពីព្រះគ្រីស្ទ។

ប្រសិនបើដំណឹងល្អគឺជាការពិត ប្រវត្តិសាស្ត្រដែលថាព្រះគ្រីស្ទបានសុគត និងបានរស់ពីសុគតឡើងវិញ ជាការពិត នោះយើងត្រូវតែបន្តការជឿរបស់យើង ទោះបីជាព្រះអង្គ មិនបានឆ្លើយតបចំពោះសេចក្តីអធិស្ឋានរបស់យើង និងយើងបានជួបប្រទះបញ្ហានៅក្នុងជីវិតយ៉ាងណាក៏ដោយ។

ប្រសិនបើដំណឹងល្អមិនមែនជាការពិត សារដែលថាព្រះគ្រីស្ទបានសុគត និងបានរស់ពីសុគតឡើងវិញមិនមែនជាការពិតរបស់ប្រវត្តិសាស្ត្រ នោះយើងគួរឈប់ជឿទៅ ទោះបីជាយើងយល់ថា ព្រះជាម្ចាស់នឹងជួយយើង តាមរយៈការឆ្លើយតបចំពោះសេចក្តីអធិស្ឋានរបស់យើងក៏ដោយ។

ការនេះ ខុសពីការយល់ឃើញរបស់មនុស្សជាច្រើន។ មនុស្សភាគច្រើនគិតថា ពួកគេជឿ ឬមិនជឿ គឺអាស្រ័យលើព្រះជាម្ចាស់ឆ្លើយតប ឬមិនឆ្លើយតបចំពោះសេចក្តីអធិស្ឋានរបស់ពួកគេ។ យើងអាចមើលឃើញហេតុការណ៍នេះផ្ទាល់នឹងភ្នែក ដោយមានអ្នកខ្លះបានឈប់ជឿ និងមានអ្នកខ្លះទៀតឈប់ទៅក្រុមជំនុំដោយហេតុថា ពួកគេមានការខកចិត្តចំពោះព្រះជាម្ចាស់ដែលមិនបានឆ្លើយតបចំពោះសេចក្តីអធិស្ឋានរបស់ពួកគេ។
នៅពេលពួកគេធ្វើយ៉ាងនេះ នោះបានសេចក្តីថា ជំនឿរបស់ពួកគេ មិនមែនជាជំនឿតាមព្រះគម្ពីរនោះទេ ពីព្រោះជំនឿតាមព្រះគម្ពីរ គឺជាជឿលើដំណឹងល្អរបស់ព្រះគ្រីស្ទ ដែលជាសារមួយអំពីអ្វីដែលព្រះជាម្ចាស់បានធ្វើនៅក្នុងប្រវត្តិសាស្ត្រ ក្នុងអំឡុងពេលប្រមាណជា២០០០ឆ្នាំមុននេះ។ ដំណឹងល្អ មិនមែនជាសារអំពីខ្ញុំ និងអំពីការឆ្លើយតបរបស់ព្រះចំពោះសេចក្តីអធិស្ឋានរបស់ខ្ញុំនោះទេ។ (ប៉ុន្តែតាមពិត ជួនកាលព្រះជាម្ចាស់ ជួយមនុស្សឲ្យមានជំនឿ តាមរយៈការឆ្លើយតប ចំពោះសេចក្តីអធិស្ឋានរបស់ពួកគេ។ ប៉ុន្តែប្រសិនបើពួកគេមានជំនឿពិតមែន នោះពួកគេនឹងមានជំនឿទៅលើដំណឹងល្អរបស់ព្រះគ្រីស្ទមិនខាន)។

នៅពេលដែលបណ្តាជនឈប់ជឿដោយព្រោះពួកគេខកចិត្តចំពោះព្រះជាម្ចាស់ ដែលមិនបានឆ្លើយតបចំពោះការអធិស្ឋានរបស់ពួកគេ នោះបានសេចក្តីថា ពួកគេរស់នៅតាមអ្វីដែលពួកគេមើលឃើញ មិនមែនតាមអ្វីដែលពួកគេបានឮនោះទេ។ ពួកគេមិនបានដើរតាមគំរូរបស់លោកអ័ប្រាហាំនោះទេ។ ប្រសិនបើលោកអ័ប្រាហាំដើរតាមអ្វីដែលលោកបានឃើញ នោះលោកមិនបានជឿថា លោកនឹងមានកូនមួយនោះទេ ពីព្រោះលោកមានវ័យចំណាស់ណាស់ហើយ។ ប៉ុន្តែផ្ទុយទៅវិញ លោកអ័ប្រាហាំបានដើរតាមអ្វីដែលលោកបានឮ គឺដើរតាមសេចក្តីសន្យារបស់ព្រះជាម្ចាស់ដែលថា លោកនឹងមានកូន។

សារនៃដំណឹងល្អសំរាប់យើង ក៏ជាសេចក្តីសន្យាដែរ ប៉ុន្តែមិនមែនជាសេចក្តីសន្យាដែលថា យើងនឹងមានកូនម្នាក់ដូចលោកអ័ប្រាហាំនោះទេ។ តែជាសេចក្តីសន្យាដែលថា ព្រះអង្គនឹងអត់ទោសបាបរបស់យើងតាមរយៈព្រះយេស៊ូវ ដើម្បីឲ្យយើងអាចផ្សះផ្សារជាមួយទ្រង់វិញ។

សេចក្តីបង្រៀននេះជួយយើងឲ្យយល់បានថា អត្ថប្រយោជន៍នៃជំនឿរបស់យើង មិនមែនស្ថិតនៅលើភាពខ្លាំងនៃជំនឿរបស់យើងនោះទេ តែស្ថិតនៅលើភាពខ្លាំងរបស់អ្នកដែលយើងបានជឿនោះវិញ។

ឧទាហរណ៍ថា ប្រសិនបើខ្ញុំអស់កម្លាំង ហើយខ្ញុំចង់សំរាកនៅលើកៅអីមួយ ហើយខ្ញុំជឿយ៉ាងមុតមាំថា កៅអីនោះ រឹងមាំល្អណាស់ បន្ទាប់មកខ្ញុំក៏អង្គុយលើកៅអីនោះ ប៉ុន្តែស្រាប់តែកៅអីនោះបាក់ តើនឹងមានអ្វីកើតឡើង? ខ្ញុំនឹងធ្លាក់បះជើងមិនខាន។ ទោះបីជាខ្ញុំមានជំនឿខ្លាំងយ៉ាងណាក៏ដោយ តែវត្ថុដែលខ្ញុំជឿនោះជាវត្ថុខ្សោយ នោះខ្ញុំនឹងដួលចុះជាមិនខាន។

ប្រសិនបើខ្ញុំងើបឈរឡើង ហើយសំឡឹងមើលកៅអីមួយផ្សេងទៀត ហើយខ្ញុំមានការសង្ស័យ ប៉ុន្តែនៅតែជឿ ហើយខ្ញុំបង្ហាញជំនឿដោយអង្គុយលើកៅអីនោះ ស្រាប់តែកៅអីនោះមិនបានបាក់នោះទេ នោះខ្ញុំក៏មិនបានធ្លាក់ពីលើកៅអីនោះដែរ ពីព្រោះវត្ថុដែលខ្ញុំជឿនោះរឹងមាំ។ ដូច្នេះ ឧទាហរណ៍នេះបង្ហាញថា ភាពខ្លាំងនៃជំនឿរបស់យើង មិនសំខាន់នោះទេ (ទោះបីជាយើងត្រូវមានជំនឿក៏ដោយ) តែអ្វីដែលសំខាន់នោះគឺ ភាពខ្លាំងរបស់អ្វីដែលយើងជឿទៅលើនោះ។
យើងបានជឿទុកចិត្តលើព្រះយេស៊ូវ នោះជាអ្វីដែលខ្លាំង រឹងមាំ ពីព្រោះទ្រង់បានរស់ពីសុគតឡើងវិញ ហេតុនោះទើបទ្រង់អាចឲ្យជីវិតអស់កល្បជានិច្ច ដល់យើង។

ដូច្នេះ យោងទៅតាមព្រះគម្ពីរ មូលដ្ឋានគ្រឹះនៃជំនឿរបស់យើង មិនមែនស្ថិតនៅលើអ្វីដែលព្រះជាម្ចាស់បានធ្វើនៅក្នុងជីវិតយើងសព្វថ្ងៃនេះនោះទេ (ទោះបីជាព្រះជាម្ចាស់បានធ្វើការរាល់ថ្ងៃ នៅក្នុងជីវិតយើងក៏ដោយ) ប៉ុន្តែស្ថិតនៅលើអ្វីដែលព្រះជាម្ចាស់បានធ្វើសំរាប់យើងក្នុងអំឡុងពេលប្រមាណជា២០០០ឆ្នាំ មកហើយនោះវិញ តាមរយៈការសុគត និងការរស់ពីសុគតឡើងវិញរបស់ព្រះយេស៊ូវ។

លើសពីនេះ តាមរយៈដំណឹងល្អ ព្រះជាម្ចាស់បានសន្យាថា យើងនឹងមានជីវិតអស់កល្បជានិច្ច។ យើងជឿលើសេចក្តីសន្យានេះតាមរយៈជំនឿ។ វាជាគោលការណ៍របស់ព្រះគម្ពីរដែលថា ជំនឿ គឺការជឿទុកចិត្តលើសេចក្តីសន្យារបស់ព្រះជាម្ចាស់ ហើយយើងទទួលសេចក្តីសន្យានោះតាមរយៈជំនឿ (រ៉ូម ៤:១៦)។

ហេតុនេះ ដំណឹងល្អដែលមាននៅក្នុងប្រវត្តិសាស្ត្រ គឺជាគ្រឹះនៃជំនឿរបស់យើង បាននាំយើងឲ្យសម្លឹងមើលអនាគត ក្នុងខណៈដែលយើងរង់ចាំទទួលនូវអ្វីដែលព្រះជាម្ចាស់បានសន្យាជាមួយយើង។ នេះជាអ្វីដែលមានបង្រៀននៅក្នុងកណ្ឌហេព្រើរ ១១ ទាំងមូល និងបានលើកឡើងនៅក្នុងហេព្រើរ ១១:១។ នេះជាហេតុផលនៃជំនឿ និងសេចក្តីសង្ឃឹម ដែលបាននៅជាមួយគ្នាយ៉ាងជិតស្និតនៅក្នុងព្រះគម្ពីរ។ តែយើងសង្ឃឹមទៅលើអ្វីដែលយើងមិនទាន់បាន មិនទាន់ឃើញនៅឡើយ (រ៉ូម ៨:២៤-២៥)។

ដូចនេះហើយបានជានៅក្នុងព្រះគម្ពីរ យើងតែងឃើញម្តងហើយម្តងទៀតថា រស់នៅដោយជំនឿ គឺរស់នៅដោយទុកចិត្តជឿជាក់លើអ្វីដែលយើងឮ (ដំណឹងល្អ) មិនមែនដើរតាមអ្វីដែលយើងមើលឃើញនោះទេ។ យើងរស់នៅដោយជំនឿ មិនមែនដោយមើលឃើញនោះទេ។

ជាថ្មីម្តងទៀត នេះខុសគ្នាស្រលះពីអ្វីដែលមនុស្សជាច្រើនបានគិត ក្នុងនោះរួមទាំងពួកជំនុំផង។ មនុស្សជាច្រើនដែលបានដាក់ខ្លួនឯងជាសំខាន់ ជាចំនុចកណ្តាល ផ្តោតទៅលើអ្វីដែលយើងត្រូវការនៅថ្ងៃនេះ ជាជាងផ្តោតសំខាន់ទៅលើព្រះគ្រីស្ទ និងសេចក្តីសង្ឃឹមនាពេលអនាគត។ ប៉ុន្តែការអនុវត្តនៅក្នុងហេព្រើរ ១១ មាននិយាយនៅក្នុងហេព្រើរ ១២:២ *ទាំងរំពឹងមើលដល់ព្រះយេស៊ូវដ៏ជាមេផ្តើម ហើយជាមេសំរេចសេចក្តីជំនឿរបស់យើង*។

នេះមិនមែនមានន័យថា យើងមិនទុកចិត្តលើព្រះជាម្ចាស់សំរាប់តម្រូវការនៅថ្ងៃនេះ របស់យើងនោះទេ។ យើងទុកចិត្តលើព្រះជាម្ចាស់ ដូចដែលព្រះយេស៊ូវបានបង្រៀនយើងឲ្យអធិស្ឋានថា «សូមប្រទានអាហារដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ» ។ ប៉ុន្តែមនុស្សជាច្រើនបានជួបបញ្ហា ដោយព្រោះតែខ្វល់ខ្វាយអំពីរឿងនៅថ្ងៃនេះ មិនបានគិតពីអតីតកាល និងអនាគតកាលឡើយ។

## *សេចក្តីជំនឿគឺជាអំណោយមកពីព្រះជាម្ចាស់* Faith is a Gift from God

បាបនិងសាតាំង បានធ្វើអោយមនុស្សខ្វាក់ភ្នែក មិនអាចមើលឃើញសេចក្តីពិតនៃដំណឹងល្អបានទេ (អេភេសូរ ៤:១៨, ២កូរិន. ៤:៤, ១កូរិន. ២:១៤, យ៉ូហាន ៦:៤៤,៦៥) រហូតទាល់តែព្រះវិញ្ញាណបរិសុទ្ធបំភ្លឺចិត្តរបស់គេ(២កូរិន. ៤:៦, ១កូរិន. ២:៩-១០)។ ហេតុដូច្នេះ វាមិនត្រឹមត្រូវទេ ដែលយើងគិតថា យើងជឿព្រះជាមុនទើបព្រះវិញ្ញាណធ្វើការក្នុងចិត្តជាក្រោយ។ ដូច្នេះសេចក្តីជំនឿ គឺជាអំណោយទានមកពីព្រះតែម្តង។

## *ហេតុអ្វីសេចក្តីជំនឿ*? Why Faith?

១-លក្ខណៈរបស់ព្រះ

នៅពេលដែលយើងពិចារណាអំពីលក្ខណៈរបស់ព្រះ និងទំនាក់ទំនងរបស់យើងចំពោះទ្រង់ នោះកាន់តែបង្ហាញអំពីមូលហេតុដែលសេចក្តីជំនឿមានសារៈសំខាន់។ ព្រះមិនមែនជាតួអង្គស្អាតស្អំខាងសីលធម៌ ដែលមិនទាក់ទងនឹងបុគ្គល ហើយដែលគ្រាន់តែអោយយើងធ្វើជាមនុស្សមានសីលធម៌ស្អាតស្អំ នោះឡើយ។ ព្រះគឺជាព្រះដែលប្រាថ្នាសាងសង់ទំនាក់ទំនងជាមួយយើងរាល់គ្នា ហើយយើងត្រូវដាក់សេចក្តីជំនឿធ្វើជាគ្រឹះនៃទំនាក់ទំនងនោះ។ ដែលវាគឺជាការឆ្លើយតបដ៏ត្រឹមត្រូវរបស់យើង ចំពោះព្រះបន្ទូលទ្រង់។ ហេតុនេះហើយ បានជាសេចក្តីជំនឿក៏មានទាក់ទងជាមួយចំណេះដឹង ការយល់ព្រមចំពោះចំណេះដឹងនោះ និងការទុកចិត្តផ្ទាល់ខ្លួនទៀតផង។

២-ការបរាជ័យរបស់យើង

នៅពេលដែលយើងពិចារណាអំពីការបរាជ័យរបស់យើង ក៏វាបង្ហាញថា សេចក្តីជំនឿមានសារៈសំខាន់ណាស់។ តាមរយៈអំពើបាបរបស់យើង មនុស្សជាតិបានត្រឡប់ជាពុករលួយអស់ ហើយមិនស្គាល់ព្រះទេ។ យើងត្រូវស្ថិតក្រោមការវិនិច្ឆ័យពីទ្រង់។ យើងមិនអាចដោះស្រាយការនេះដោយការល្អរបស់ខ្លួនបានទេ។ ព្រះបានដោះស្រាយបញ្ហានេះដោយសារដំណឹងល្អនៃព្រះគ្រីស្ទ ហើយសេចក្តីជំនឿ គឺជាការឆ្លើយតបដ៏ត្រឹមត្រូវចំពោះដំណឹងល្អ។ ហេតុនេះហើយបានជាសេចក្តីជំនឿ គឺជាវិធីដែលយើងអាចចាប់យកដំណោះស្រាយរបស់ព្រះបាន មិនមែនដោយការប្រឹងប្រែងធ្វើការល្អរបស់យើង ឬការស្ទឹងស្មាធអ្វីនោះទេ។

## *ដោយជំនឿមិនមែនដោយការមើលឃើញនឹងភ្នែក* Faith not Sight

យើងបានមើលឃើញក្នុងរ៉ូម១០ ហើយថាសេចក្តីជំនឿ គឺជាការឆ្លើយតបដ៏ត្រឹមត្រូវរបស់មនុស្សជាតិ ចំពោះការលើព្រះបន្ទូលព្រះ។ ហេតុនេះ សេចក្តីជំនឿដើរតាមក្រោយការស្តាប់លឺ មិនមែនការមើលឃើញនោះទេ។ ព្រះគម្ពីរលើកទឹកចិត្តយើងអោយរស់នៅដោយសេចក្តីជំនឿ មិនមែនដោយការមើលឃើញនោះទេ (២កូរិន. ៤:១៨, ៥:៧, ហេព្រើ ១១:១)។ នេះគឺជាខ្លឹមសារជាបន្តបន្ទាប់ក្នុងព្រះគម្ពីរ។ ឧទាហរណ៍ នេះជាគំរូពីលោកអាប្រាហាំ។ ។ ហេតុនោះហើយ អាប្រាហាំបានរស់នៅដោយសារសេចក្តីជំនឿ មិនមែនដោយសារការមើលឃើញនឹងភ្នែកនោះទេ។ នៅពេលដែលពួកភ្នាក់ងារទាំង

១២នាក់ចុះទៅស៊ើបការណ៍នៅទឹកដីសន្យា ១០នាក់បានសំរេចចិត្តថាមិនត្រូវវាយយកស្រុកនោះទេ បើតាមតែអ្វីដែលភ្នែកគេមើលឃើញ។ មានតែយ៉ូស្វេ និងកាលែបទេ ដែលបានរស់នៅដោយសេចក្តីជំនឿ មិនមែនដោយការមើលឃើញ ហើយបានជឿថា ពួកគេអាចចូលក្នុងទឹកដីសន្យាបាន។ សូមកត់សម្គាល់ ថាមានតែពីរនាក់នេះប៉ុណ្ណោះក្នុងចំណោមមនុស្សពេញវ័យ ដែលបានចាកចេញពីអេស៊ីព្ទមក ហើយដែលបានរស់ដោយសេចក្តីជំនឿ ហើយអាចចូលក្នុងទឹកដីសន្យាបាន។ ម្តងទៀត ការនេះបង្ហាញអំពីសារៈសំខាន់នៃសេចក្តីជំនឿ។ សូមកត់សម្គាល់ផងដែរអំពីសេចក្តីជំនឿរបស់លោកយ៉ូស្វេ និងរបស់លោកកាលែបដែលជាការជឿលើអ្វីដែលព្រះបានសន្យា។ សេចក្តីជំនឿរបស់គេ មិនគ្រាន់តែជឿថាព្រះមានពេញដោយអំណាចដើម្បីឲ្យគេអាចចូលទៅកាន់ទឹកដីនោះប៉ុណ្ណោះទេ ប៉ុន្តែគឺជាការជឿថា ព្រះអាចនឹងច្បាស់ជាធ្វើអ្វីដែលទ្រង់បានសន្យារួចហើយ។ ពួកព្យាការី ជាពិសេសលោកអេសាយ បានលើកទឹកចិត្ត ជាច្រើនដងដល់ជនជាតិអ៊ីស្រាអែល អោយរស់នៅដោយសេចក្តីជំនឿ មិនមែនដោយការមើលឃើញឡើយ។

## *សេចក្តីជំនឿ និងព្រះបន្ទូលរបស់ព្រះ* Faith and God's Word

ដូចដែលយើងបានមើលឃើញពីមុនមក សេចក្តីជំនឿចេញមកពីការស្តាប់លឺព្រះបន្ទូលព្រះ។ ហេតុនេះ គ្រីស្ទបរិស័ទគួរតែបន្តស្តាប់ដោយយកចិត្តទុកដាក់ចំពោះព្រះបន្ទូលព្រះដើម្បីអោយគេអាចពង្រឹងសេចក្តីជំនឿរបស់ខ្លួនបាន (ហេព្រើ ៤) ។

## *សេចក្តីជំនឿ និងការប្រែចិត្ត* Faith and Repentance

សេចក្តីជំនឿដ៏ពិតមិនអាចកាត់ផ្តាច់ចេញពីការប្រែចិត្តបានទេ ទាំងពីរនេះត្រូវតែចងភ្ជាប់គ្នា។ សេចក្តីជំនឿដ៏ពិត គឺជាការងារមករកព្រះយេស៊ូវសូមការអត់ទោសបាប ហើយត្រូវតែមើលឃើញភាពអាក្រក់នៃបាប ហើយតែងតែងាកចេញពីវាមករកព្រះយេស៊ូវវិញ។ លើសពីនេះ ការប្រែចិត្ត និងសេចក្តីជំនឿជារបៀបដែលយើងគ្រាន់តែចាប់ផ្តើមជីវិតគ្រីស្ទបរិស័ទនោះទេ តែជាការបន្តរស់នៅក្នុងជីវិតជាគ្រីស្ទបរិស័ទជានិច្ច (វិវរណៈ ៣:១៩, កាឡាទី ២:២០)។ អាស្រ័យហេតុនេះ នៅពេលដែលយើងអធិប្បាយ យើងមិនត្រូវគិតថា ការដឹកនាំមនុស្សអោយមានជំនឿ និងការប្រែចិត្ត គឺជាអ្វីដែលយើងគ្រាន់តែធ្វើដល់អ្នកមិនមែនជាគ្រីស្ទបរិស័ទ ហើយមិនយកសេចក្តីនោះមកអធិប្បាយចំពោះគ្រីស្ទបរិស័ទនោះឡើយ។ តាមពិត ការដែលដឹកនាំមនុស្សអោយមានជំនឿលើព្រះយេស៊ូវ និងមានការប្រែចិត្តចំពោះទ្រង់ ត្រូវតែជាគោលដៅរបស់យើងជានិច្ចក្នុងការអធិប្បាយ។

## *សេចក្តីជំនឿ និងការអរព្រះគុណ* Faith and Thanksgiving

សេចក្តីជំនឿដ៏ពិត ពឹងផ្អែកលើសេចក្តីសន្យារបស់ព្រះ ចេះអរគុណចំពោះព្រះគុណរបស់ព្រះដោយធ្វើការសំរាប់សិរីល្អរបស់ព្រះ។ នៅពេលយើងមានជំនឿ យើងទទួលស្គាល់ថា យើងមិនអាចសង្គ្រោះខ្លួនឯងបានឡើយ។ ដូច្នេះ សេចក្តីជំនឿគួរតែបន្ទាបយើងចុះ ហើយដឹកនាំយើងអោយមានជីវិតដែលចេះដឹងគុណផង។

## *សេចក្តីជំនឿ និងការអធិស្ឋាន* Faith and Prayer

មធ្យោបាយមួយដ៏ជាក់លាក់ ក្នុងការបង្ហាញចេញសេចក្តីជំនឿរបស់យើងលើព្រះ គឺដោយសារការអធិស្ឋានរបស់យើង។ ទោះយ៉ាងណាក៏ដោយ មិនគ្រាន់តែជាបរិមាណដែលយើងអធិស្ឋានដែលបង្ហាញនូវ សេចក្តីជំនឿរបស់យើងប៉ុណ្ណោះទេ

ប៉ុន្តែគឺជាអ្វីដែលយើងទូលសូមទៅវិញ។ បើសិនជាយើង *គ្រាន់តែ* អធិស្ឋាន ទូលសូមតែអ្វីៗដែលស្ដីអំពីសេចក្ដីត្រូវការផ្ទាល់ខ្លួនជានិច្ច នោះបង្ហាញថា យើងមិនទាន់បានរៀនអំពីគំរូរបស់ព្រះយេស៊ូវក្នុងការអធិស្ឋានក្នុងម៉ាថាយជំពូក៦នៅឡើយទេ។ ការអធិស្ឋានចាប់ផ្ដើមដោយការយកចិត្តទុកដាក់ដល់*ព្រះនាមដ៏បរិសុទ្ធ**របស់ព្រះ* *នគររបស់ទ្រង់* *និង* *បំណងព្រះហឫទ័យ**របស់ទ្រង់* ។ សេចក្ដីជំនឿរបស់យើងគួរតែដាក់ការយកចិត្តទុកដាក់ទាំងនេះខ្ពស់លើសជាងអ្វីទាំងអស់ក្នុងចិត្តយើង និងក្នុងការអធិស្ឋានរបស់យើងផងដែរ។

# *សង្ខេប*

យើងបានមើលឃើញពីធាតុសំខាន់ៗជាច្រើន អំពីជំនឿ។

១. ជំនឿ គឺជាការជឿលើព្រះយេស៊ូវ ជឿលើដំណឹងល្អដែលជាសារមួយ អំពីអ្វីដែលព្រះជាម្ចាស់បានធ្វើសំរាប់យើង*នៅក្នុងប្រវត្តិសាស្ត្រ* តាមរយៈព្រះគ្រីស្ទ២០០០ឆ្នាំកន្លងមកនេះ នៅក្នុងការសុគត និងការរស់ពីសុគតឡើងវិញរបស់ទ្រង់។ គ្រប់គ្នាត្រូវតែឮសារនេះ ដើម្បីឲ្យពួកគេអាចជឿបាន។

២.ដំណឹងល្អនេះបានផ្ដល់ឲ្យយើងនូវព្រះបន្ទូលនៃសេចក្ដីសន្យា និងជំនឿរបស់យើងនៅក្នុងសេចក្ដីសន្យាទាំងអស់នោះ។ សេចក្ដីសន្យាទាំងនេះនាំយើងឲ្យសំឡឹងមើលទៅថ្ងៃ*អនាគត* ក្នុងខណៈពេលដែលយើងកំពុងរង់ចាំការយាងត្រលប់មកវិញរបស់ព្រះគ្រីស្ទ។

៣. ជំនឿ គឺជាការដាក់ការ*ទុកចិត្ត*របស់យើងទៅលើព្រះយេស៊ូវ មានន័យថា យើងមិនអាចដាក់ជំនឿទៅលើខ្លួនឯងបានឡើយ។ យើងមិនអាចទុកចិត្តចំពោះអំពើល្អរបស់យើង ដើម្បីទទួលបាននូវសេចក្ដីសង្គ្រោះ និងជីវិតអស់កល្បជានិច្ចនោះឡើយ។




៤. ភាពខ្លាំងនៃជំនឿរបស់យើង មិនមែនជាអ្វីដែលសំខាន់នោះទេ (ទោះបីជាយើងចាំបាច់ត្រូវមានជំនឿក្ដី) តែការដែលសំខាន់នោះគឺ ភាពខ្លាំងនៃអ្វីដែលយើងបានជឿលើនោះវិញ។

៥. ការអនុវត្តៈ ដំណឹងល្អអំពីព្រះគ្រីស្ទគឺជាការពិត ក្នុងនោះ ព្រះគ្រីស្ទបានសុគត រស់ពីសុគតឡើងវិញ និងត្រូវយាងមកម្ដងទៀត ដូច្នេះត្រូវរក្សាជំនឿទៅលើទ្រង់ មិនថាមានអ្វីកើតឡើងនៅក្នុងជីវិតរបស់យើងយ៉ាងណាក៏ដោយ។